# កិច្ចប្រជុំត្រៀមគណៈកម្មាធិការសម្របសម្រួលចម្រុះ ថ្នាក់រដ្ឋមន្ត្រី ស្តីពីតំបន់អភិវឌ្ឍន៍ត្រីកោណ កម្ពុជា ឡាវ វៀតណាម (CLV-DTA) នៅទីស្តីការក្រសួងពាណិជ្ជកម្ម

យោងតាមលេខរៀងគិតតាមលំដាប់អក្សរ ក្នុងឆ្នាំ២០១០ នេះ កម្ពុជា ត្រូវធ្វើជាម្ចាស់ផ្ទះ ក្នុងការរៀបចំកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលចម្រុះ ថ្នាក់រដ្ឋមន្ត្រី ស្តីពីតំបន់អភិវឌ្ឍន៍ ត្រីកោណ កម្ពុជា ឡាវ វៀតណាម (CLV-DTA) កិច្ចប្រជុំអនុគណៈកម្មការនានា កិច្ចប្រជុំឧត្តមមន្ត្រី កិច្ចប្រជុំបច្ចេកទេសចម្រុះ កិច្ចប្រជុំជាមួយដៃគូរអភិវឌ្ឍន៍ផ្សេងៗ សន្និសីទនៃការជំរុញពាណិជ្ជកម្ម វិនិយោគ និងទេសចរណ៍ ព្រមទាំងរៀបចំព្រឹត្តិការណ៍ផ្សេងៗទៀត ទន្ទឹមគ្នាផងដែរនោះ នៅព្រឹកថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០ នៅទីស្តីការក្រសួងពាណិជ្ជកម្ម មានរៀបចំកិច្ចប្រជុំត្រៀម គណៈកម្មាធិការសម្របសម្រួលចម្រុះថ្នាក់រដ្ឋមន្ត្រី ស្តីពីតំបន់អភិវឌ្ឍន៍ ត្រីកោណ កម្ពុជា ឡាវ វៀតណាម (CLV-DTA) ក្រោមអធិបតីភាព ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាប្រធានគណៈកម្មាធិការជាតិសម្របសម្រួល សំរាប់កម្ពុជា ដោយមានការចូលរួមពី ឯកឧត្តម លោកជំទាវ អស់លោក-លោកស្រី ជាអនុប្រធាន និងសមាជិកនៃ គណៈកម្មា ធិការជាតិសម្របសម្រួល តំណាងអភិបាលខេត្ត ទាំង៤ ដែលស្ថិតក្នុងតំបន់ត្រីកោណអភិវឌ្ឍន៍ រួមមាន ខេត្ត ក្រចេះ ស្ទឹងត្រែង រតនៈគីរី និងមណ្ឌលគីរី ។

ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានមានប្រសាសន៍ថាៈការត្រៀមរបស់កម្ពុជា ក្នុងការរៀបចំកិច្ចប្រជុំ ស្តីពីតំបន់អភិវឌ្ឍន៍ត្រីកោណ កម្ពុជា ឡាវ វៀតណាម និងព្រឹត្តិការណ៍ផ្សេងៗទៀត ដែលកម្ពុជា ត្រូវធ្វើជាម្ចាស់ផ្ទះនោះ ត្រូវបានការឯកភាពដ៏ខ្ពង់ខ្ពស់ពីសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០១០ រួចហើយ ។ ដូច្នេះកិច្ចប្រជុំនាឱកាសនេះ គឺដើម្បីពិភាក្សា ក្នុងគណៈកម្មាធិការជាតិសម្របសម្រួល ដើម្បីត្រៀមដំណើរការកិច្ចប្រជុំនេះឱ្យបានជោគជ័យ ហើយយើងអាចរៀបចំឯកសារមានលក្ខណៈប្រវត្តិសាស្ត្របានទាន់ពេលវេលា សំរាប់ឈានទៅរៀបចំកិច្ចប្រជុំកំពូល ដែលគ្រោងធ្វើ នៅកម្ពុជាផងដែរ នៅចុងឆ្នាំ២០១០ ខាងមុខនេះ ។

ឆ្លងកាត់ការពិភាក្សារួចមក អង្គប្រជុំបានសម្រេច យក ខេត្ត រតនៈគីរី ជាទីតាំងសមស្របសំរាប់រៀបចំកិច្ចប្រជុំ និងព្រឹត្តិការណ៍ផ្សេងៗតាមកម្មវិធីដូចខាងក្រោមៈ

**១-** នៅថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០១០ រៀបចំវេទិការយុវជនតំបន់ត្រីកោណ កម្ពុជា ឡាវ វៀតណាម

**២-** នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១០ សម្ពោធពិព័រណ៍ពាណិជ្ជកម្មតំបន់អភិវឌ្ឍន៍ត្រីកោណ កម្ពុជា ឡាវ វៀតណាម

**៣-** ថ្ងៃទី១៥ ខែ មីនា ឆ្នាំ២០១០ សន្និសីទ ជំរុញពាណិជ្ជកម្ម វិនិយោគ និងទេសចរណ៍

**៤-** ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១០ កិច្ចប្រជុំអនុគណៈកម្មាធិការ សន្តិសុខ និងការបរទេស-សេដ្ឋកិច្ច-សង្គមកិច្ច និង បរិស្ថាន

**៥-** ថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០១០ កិច្ចប្រជុំថ្នាក់ឧត្តមមន្ត្រី នៃប្រទេស កម្ពុជា ឡាវ វៀតណាម

**៦-** ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលចម្រុះថ្នាក់រដ្ឋមន្ត្រី ស្តីពីតំបន់អភិវឌ្ឍន៍ ត្រីកោណ កម្ពុជា ឡាវ វៀតណាម ។